ឈើទាំងនោះត្រូវបានកាន់កាប់ដោយសហគមន៍ ពាណិជ្ជករ និងពួកអ្នកមានអំណាចមួយចំនួនក្តី។ រដ្ឋបាលព្រៃឈើបាន កំណត់កម្មវត្ថុនៃការដាំដើមឈើចំនួនបីគឺដើម្បី ការកាត់បន្ថយភាពក្រីក្រ ការការពារបរិស្ថាន និងការអភិវឌ្ឍន៍ សេដ្ឋកិច្ច ដែលនេះជាការឆ្លុះបញ្ចាំងដោយផ្ទាល់ពីសេចក្តីថ្លែងការស្តីពីគោលនយោបាយវិស័យព្រៃឈើរបស់រាជរដ្ឋាភិបាល (2002) ដែលថា:

រាជរដ្ឋាភិបាលកម្ពុជាយកចិត្តទុកដាក់ចំពោះការអភិរក្ស និងគ្រប់គ្រងធនធានព្រៃឈើដោយធានាភាពស្ថិតស្ថេរនៃអេកូឡូស៊ី សង្គម និង សេដ្ឋកិច្ច ដែលជាសរសរគ្រឹះមួយយ៉ាងសំខាន់សំរាប់សុខុមាលភាពសាធារណៈ និង ជាវិភាគទានដោយផ្ទាល់ចំពោះការការពារបរិស្ថាន ការកាត់បន្ថយភាពក្រីក្រ និង ការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម។

រដ្ឋបាលព្រៃឈើនឹងយកចិត្តទុកដាក់ជាពិសេស ចំពោះការជំនួសការផ្គត់ផ្គង់ឈើដោយព្រៃធម្មជាតិទៅជាការផ្គត់ផ្គង់ដោយចំការព្រៃដាំ តាមរយៈការលើកទឹកចិត្តឱ្យមានការវិនិយោគជាលក្ខណៈឯកជន និង ការចូលរួមពីសាធារណៈជនទូទៅ (DFW, 2002a)។ ផែនការដាំឈើរយៈពេលវែងត្រូវតែរៀបចំឡើង ដែលក្នុងនោះរដ្ឋបាលព្រៃឈើថ្នាក់កណ្តាលទទួលខុសត្រូវលើកិច្ចសហប្រតិបត្តិការជាអន្តរជាតិ និង កម្មវិធីដាំឈើជាទ្រង់ទ្រាយធំ ចំណែកឯរដ្ឋបាលព្រៃឈើនៅមូលដ្ឋាន ជំរុញ លើកទឹកចិត្តដល់ការដាំឈើជាទ្រង់ទ្រាយតូច និងការដាំឈើដោយសហគមន៍។

## ៥.ទម្រង់នានានៃការងារដាំឈើ

ការអនុវត្តសកម្មភាពដាំដើមឈើ អាចនឹងទទួលបានជោគជ័យធំធេងនៅទីណាដែលការកាន់កាប់ដីត្រូវបានធានាក្នុងរយៈពេលយូរអង្វែង តម្រូវការរបស់មូលដ្ឋានត្រូវបានបំពេញ ហើយសេចក្តីសំរេចចិត្តត្រូវបានទទួលយកដោយសង្គមទាំងមូល (ITTO 1993)។ នៅក្នុង បរិបទនៃគោលការណ៍ណែនាំនេះ ការដាំដើមឈើអាចមានន័យថា (សូមមើលផ្នែកទី ២ អំពីគោលការណ៍ណែនាំបច្ចេកទេស):

- ការស្តារឡើងវិញនូវដីព្រៃរេចរិល និងព្រៃដុះឡើងវិញ
- សកម្មភាពដាំដើមឈើដោយសហគមន៍
- ការបង្កើតចំការឈើដាំជាទ្រង់ទ្រាយធំ
- ការដាំដើមឈើនៅលើដីចំការឯកជន

## ៥.១ ការស្តារឡើងវិញដីព្រៃរេចរិលនិងព្រៃដុះឡើងវិញ

ផ្ទៃដីព្រៃរេចរិលនិងព្រៃដុះឡើងវិញមានវិសាលភាពធំធេងនៅក្នុងបណ្តាប្រទេសនៅអាស៊ី។ ការស្តារដីព្រៃរេចរិលឡើងវិញឱ្យក្លាយទៅជាព្រៃផ្តល់ផលច្រើនមុខគឺជាការងារដែលមានសារសំខាន់បំផុតព្រោះព្រៃឈើប្រភេទនេះនឹងផ្តល់នូវផលិតផលឈើមូល ផលិតផលក្រៅពីឈើ ការចិញ្ចឹមជីវិតប្រចាំថ្ងៃ និង ផលប្រយោជន៍ខាងបរិស្ថាន។ កាស្តារនិងគ្រប់គ្រងដីព្រៃរេចរិលត្រូវពិនិត្យមើលនៅក្នុងវិសាលភាពធំទូលាយ ហើយនៅក្នុងទំរង់នៃផែនការអភិវឌ្ឍន៍ដោយនិរន្តរភាព ក្នុងន័យធានានូវវិសាលភាពនៃដែនព្រៃឈើ និងការប្រើប្រាស់ដីផ្សេងៗ ទៀតស្របតាមតំរូវការសង្គម (ITTO, 2002)។

ផ្ទៃដីព្រៃរេចរិលទាំងនោះ ជារឿយៗត្រូវបានបំលែងទៅជាចំការឈើសំរាប់ធ្វើម្សៅក្រដាសនិងចំការដំណាំកសិកម្មដែលជាដំណើរការមួយភ្លេចពិចាណាអំពីតំលៃខាងផ្នែកសេដ្ឋកិច្ចដ៏ធំធេងប្រសិនបើព្រៃរេចរិលនោះត្រូវបានស្តារឡើងវិញ។ប្រសិនបើវាយតម្លៃដោយផ្អែកទៅលើផ្នែកហិរញ្ញវត្ថុតែមួយមុខ គេឃើញថាការស្តារដីព្រៃរេចរិលឡើងវិញមានតម្លៃខ្ពស់ជាងការដាំឈើជាលក្ខណៈឧស្សាហកម្ម ប៉ុន្តែគេភ្លេចគិតអំពីកំរិតនៃផលធៀបរវាងចំណាយនិងចំណូលនៃយុទ្ធសាស្ត្រគ្រប់គ្រងផ្សេងៗគ្នាសំរាប់ព្រៃរេចរិល។ ឧទាហរណ៍ ជីវចំរុះមិនត្រូវបានជួបប្រទះនៅក្នុងចំការឈើដាំជាលក្ខណៈឧស្សាហកម្មទេ ហើយនៅក្នុងចំការឈើរបៀបនេះ គេមិនបានពិចារណាអំពីតំលៃខាងសង្គមដែលកើតឡើងដោយការប្រើប្រាស់កំលាំងពលកម្មដ៏ច្រើននៅក្នុងកិច្ចអន្តរាគមន៍វុទ្ធវប្បកម្ម ហើយផលិតផលដែលទទួលបានមានតែឈើតែមួយមុខគត់ ដោយមើលរំលងនូវសក្តានុពលដ៏ធំធេងនៃលិតផលផ្សេងៗទៀត។

ទោះបីជាផ្ទៃដីព្រៃឈើដែលរេចរិលដ៏ធំធេងនៃប្រទេសកម្ពុជាត្រូវបានគេគិតថាទាមទារឱ្យមានការស្តារឡើងវិញក្តី ក៏មកទល់នឹងពេលនេះមិនទាន់មានគោលការណ៍ណែនាំណាមួយដើម្បីតំរង់ទិសការងារនេះនៅឡើយទេ។ នយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលតាមរយៈការធ្វើសម្បទានដី អាចនឹងឈានដល់ការផ្តល់ដីព្រៃរេចរិលសំរាប់ការដាំឈើជាលក្ខណៈឧស្សាហកម្ម។ ម៉្យាងវិញទៀត ការផ្តល់ដីទាំងនេះទៅជាដីសម្បទានសង្គម ឬក៏ទៅឱ្យសហគមន៍គ្រប់គ្រង នឹងជួយរួមចំណែកដោយផ្ទាល់ក្នុងការកាត់បន្ថយភាពក្រីក្រ នឹងការស្តារដីព្រៃរេចរិលឡើងវិញ។

វិធីសាស្ត្រនានាក្នុងការដាំដើមឈើដើម្បីស្តារដីព្រៃឈើឡើងវិញមានាពខុសៗគ្នាអាស្រ័យលើកំរិតនៃភាពរេចរិលរបស់ព្រៃឈើ ឧទាហរណ៍:

- ការដាំបញ្ចូលទៅក្នុងតំបន់ដែលធ្វើអាជីវកម្មហើយ ជាវិធីសាស្ត្រមួយដែលគេនិយមប្រើក្នុងការស្តារដីព្រៃក្រោយការធ្វើអាជីវកម្ម ដោយផ្តោតជាសំខាន់លើការប្រើប្រាស់ប្រភេទឈើពាណិជ្ជកម្ម
- ការជួយជំរុញឱ្យមានដំណុះព្រៃដោយធម្មជាតិ វិធីនេះពឹងផ្អែកលើគោលការណ៍អេកូឡូស៊ីនៃដំណើរវិវឌ្ឍន៍របស់ព្រៃឈើ
- ការប្រើប្រាស់បច្ចេកទេស framework species ដែលជាការដាំចំរុះគ្នា ពី ២០-៣០ ប្រភេទ នូវប្រភេទឈើដែលងាយបោះទីតាំងមុន និងប្រភេទឈើនៃសារព័ន្ធព្រៃពេញរូបរាង្គ នៅក្នុងតំបន់រេចរិលខ្លាំង។
- គួរកត់សំគាល់ថា សំរាប់តំបន់ព្រៃដែលមានការខូចខាតមធ្យមឬតិចតួច ការគ្រប់គ្រងដោយពឹងផ្អែកលើគោលការណ៍អេកូឡូស៊ីនៃដំណើរ វិវឌ្ឍន៍របស់ព្រៃឈើគឺប្រសើរជាងការងារដាំដើមឈើឡើងវិញ។

## ៥.២ សកម្មភាពដាំដើមឈើដោយសហគមន៍

នៅបណ្តាទសវត្សចុងក្រោយនេះ បណ្តាលិខិតបទដ្ឋានច្បាប់ និង នយោបាយព្រៃឈើមាននិន្នាការជំរុញការគ្រប់គ្រងព្រៃឈើដោយសហគមន៍មូលដ្ឋាន ហេតុការណ៍នេះបានផ្តល់ឱកាសសមស្របសំរាប់ការអនុវត្តន៍យុទ្ធសាស្ត្រស្តារនិងគ្រប់គ្រងដែនព្រៃរេចរិល និងព្រៃដុះឡើងវិញ។ ការយល់ដឹងឬគំនិតអំពីសហគមន៍ព្រៃឈើមិនមែនជារឿងថ្មីទេ ក៏ប៉ុន្តែគំនិតនេះទើបតែបានផុសចេញនាពេលថ្មីៗនេះដើម្បីឆ្លើយតបទៅនឹងបរាជ័យនៃឧស្សាហកម្មព្រៃឈើជាទ្រង់ទ្រាយធំក្នុងការរួមវិភាគទានដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម។ បទពិសោធន៍បានបង្ហាញថា សហគមន៍មូលដ្ឋានបានរៀបចំខ្លួនជាស្រេចដើម្បីទទួលយកនូវការទទួលខុសត្រូវក្នុងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ដើម្បីជាផ្នូរនឹងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម និង ផលប្រយោជន៍ក្នុងការប្រើប្រាស់ព្រៃឈើ។

ប្រហែលមួយភាគបួននៃដែនព្រៃឈើនៃប្រទេសកំពុងអភិវឌ្ឍន៍ ត្រូវបានកាន់កាប់ដោយប្រគល់ជាកម្មសិទ្ធិ (១៤%) ឬគ្រប់គ្រងជាផ្លូវការ (៨%) ដោយប្រជាជនមូលដ្ឋាន នេះជាលទ្ធផលនៃការទទួលស្គាល់ដោយរដ្ឋាភិបាលនូវការទាមទារ និង ការធ្វើវិមជ្ឈការទៅកាន់មូលដ្ឋាន (Wunder, 2001, cited in Scherr *et al.*, 2002)។

ជីវភាពប្រចាំថ្ងៃនៃប្រជាជនកម្ពុជានៅជនបទភាគច្រើន ពឹងផ្អែកទៅលើការចូលរុករកផលិតផលព្រៃឈើសំរាប់ជាអាហារ អុស សរសរ បង្គោល ចៀវជ័រ ចំណីសត្វ ឱសថបូរាណ និងផលិតផលមិនមែនឈើផ្សេងៗទៀត។ ក៏ប៉ុន្តែ នៅក្នុងតំបន់ជនបទភាគច្រើន ធានធានព្រៃឈើកាន់តែរួញរៀវទៅៗ ឬក៏ត្រូវបាត់បង់ទាំងស្រុង បង្កឱ្យមានការលំបាកក្នុងការចូលទៅក្នុងព្រៃ ម៉្យាងដោយសារចំងាយឆ្ងាយ ម៉្យាងទៀតដោយសារសំពាធនៃការកើនចំនួនប្រជា

ជន និងការហាមឃាត់មិនឱ្យចូលព្រៃ។ ក្នុងបរិបទនៃផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ តំរូវការឱ្យមានការដាំដើមឈើឡើងវិញអាចនឹងត្រូវគេដាក់បញ្ចូលដើម្បីជំនះនូវការបាត់បង់នេះ។

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះគេពិនិត្យឃើញមានការកើនឡើងនូវសកម្មភាពសហគមន៍ព្រៃឈើដែលផ្តល់សិទ្ធគ្រប់គ្រងព្រៃទៅឱ្យសហគមន៍ ដែលនេះជាសញ្ញានៃការផ្តល់ការលើកទឹកចិត្តឱ្យមានការប្រើប្រាស់ព្រៃឈើប្រកបដោយនិរន្តរភាព។ ជាទូទៅគេពិនិត្យឃើញថាភាគច្រើននៃកិច្ចព្រមព្រៀងសហគមន៍ព្រៃឈើ គ្រប់គ្រងតំបន់ព្រៃរេចរិលខ្លាំងដែលជាតំបន់ទាមទារឱ្យមានការស្តារដីព្រៃឡើងវិញ។ ការចូលរួមពីសហគមន៍មូលដ្ឋាន ក្នុងសកម្មភាព ដាំដើមឈើអាចនឹងត្រូវពង្រីកតាមរយៈកិច្ចព្រមព្រៀងសហការជាមួយនឹងបណ្តាអ្នកពាក់ព័ន្ធនានា។

គ្រួសារក្រីក្រនៅជនបទជាច្រើនបានដាំដើមឈើនៅលើដីដែលគេគិតថាមានសុវត្ថិភាព ដូចជាដីសំរាប់ដាំដំណាំកសិកម្មដីភូមិករនិងដីសាធារណៈ។ និន្នាការនេះបង្ហាញនូវតំរូវការឱ្យមានការធ្វើសមាហរណកម្មនៃវិស័យព្រៃឈើទៅក្នុងវិសាលភាពនៃវិស័យកសិកម្មដូច្នេះទាមទារឱ្យមានការធ្វើផែនការដោយមានការចូលរួមពីស្ថាប័នពាក់ព័ន្ធនានា។

យុទ្ធសាស្ត្រជំរុញការចូលរួមដាំដើមឈើនៅតំបន់ដីព្រៃរេចរិល ត្រូវតែផ្តោតជាសំខាន់ទៅលើប្រជាជនមូលដ្ឋាន។ ពួកគេត្រូវតែទទួលបាននូវសុវត្ថិភាពនៃការកាន់កាប់និងសិទ្ធិនៃការប្រើប្រាស់ ការបង្កើនគុណភាពនៃផលិតផលសំរេចរួមបញ្ចូលទាំងការបង្កើតភាពជាដៃគូររវាងសហគមន៍មូលដ្ឋាន និងសហគ្រាសជំនួញខាងព្រៃឈើ។ ដោយទទួលស្គាល់យ៉ាងពេញទំហឹងនូវលទ្ធភាពរបស់ព្រៃឈើក្នុងការចូលរួមកាត់បន្ថយភាពក្រីក្រ សកម្មភាពនានាទាក់ទងនឹងព្រៃឈើត្រូវតែបញ្ចូលទៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទដ៏ទូលំទូលាយ (Sunderlin *et al.*, 2004)។

## ៥.៣ ការបង្កើតចំការឈើដាំជាទ្រង់ទ្រាយធំ

ចំការឈើដាំជាទ្រង់ទ្រាយធំប្រហែលជាសមស្របប្រសិនជាគេបង្កើតនៅក្នុងតំបន់ដែលមិនមែនជាព្រៃឈើ ឬក៏នៅក្នុងតំបន់ព្រៃដែលទទួលរងការខូចខាតឬរេចរិលខ្លាំងមិនអាចស្តារឡើងវិញបាន។ គេមិនត្រូវកាប់ព្រៃធម្មជាតិហើយដាំដើមឈើវិញនោះទេ ដោយសារចំការឈើដាំមិនអាចជំនួសព្រៃធម្មជាតិបាន មិនអាចជាប្រភពនៃវត្ថុធាតុដើម ហើយក៏មិនអាចទទួលយកផលប្រយោជន៍ផ្នែកបរិស្ថាននិងសង្គមបានទេ។

អ្វីដែលត្រូវការជាបឋមក្នុងការបង្កើតចំការឈើដាំនោះគឺថា ក្នុងដំណើរការផ្តល់ដីគេត្រូវពិចារណាអំពីផលប្រយោជន៍ និងសិទ្ធិស្របច្បាប់របស់ភាគីពាក់ព័ន្ធ ឬក៏របស់ភាគីដែលទទួលផលប៉ះពាល់ពីគំរោងនេះ ដោយត្រូវគិតគូរជាពិសេសលើផលប្រយោជន៍ និងការកាន់កាប់ដីតាមផ្លូវច្បាប់របស់សហគមន៍មូលដ្ឋាន។ គេត្រូវគិតគូរផងដែរអំពី

តំរូវការនាពេលបច្ចុប្បន្ន និង អនាគតនូវផ្ទៃដីសំរាប់ប្រកបរបរកសិកម្ម ចិញ្ចឹមសត្វ និង ការប្រើប្រាស់ជាប្រពៃណីនៃផលិតផលព្រៃឈើជាច្រើនប្រភេទ ព្រមទាំងការអភិរក្ស (ITTO, 1993) ។

ប្រសិនបើរៀបចំធ្វើផែនការបានត្រឹមត្រូវ នោះចំការឈើដាំជាលក្ខណៈពាណិជ្ជកម្ម អាចទទួលបានផលិតផលខ្ពស់ដែលអាចចូលរួមវិភាគទានយ៉ាងសំខាន់ដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ តាមរយៈប្រាក់ចំណូលដែលបានមកពីការនាំចេញដែលមានស្ថេរភាព ដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមតាមរយៈការចូលទៅដល់ប្រភពធនធាន ឱកាសបំពេញការងារ ការកែលំអហេដ្ឋារចនាសម្ព័ន្ធ។ ឧទាហរណ៍ចំការឈើដាំនៅប្រទេសញូសេឡែន និងប្រទេសឈីលី បានផ្គត់ផ្គង់ គ្រប់គ្រាន់ដល់តំរូវការប្រើប្រាស់ក្នុងស្រុក ហើយអាចនាំចេញទៅក្រៅប្រទេសបានទៀតផង (Rollinson, 2003)។ ទោះជាយ៉ាងនេះក្តី ចំការឈើដាំជាច្រើនមិនអាចបំពេញសេចក្តីសង្ឃឹមនេះបានទេ ដោយសារមិនមានការថែទាំឱ្យបានជិតដល់ហើយមិនមានទីផ្សារសំរាប់ប្រភេទឈើដែលបានដាំ។

## ៥.៣.១ ចំការឈើតែមួយប្រភេទ

ការដាំឈើជាទ្រង់ទ្រាយធំជារឿយៗត្រូវបានគេឃោសនាថាត្រូវចំណាយដើមទុនតិច ប្រឈមនឹងគ្រោះថ្នាក់តិចតួចនិងផ្តល់ទិន្នផលខ្ពស់ជាមួយនឹងលទ្ធផលឯកសណ្ឋាននិងអាចទស្សន៍ទាយជាមុនបាន (Mayer and Vermeulen ,2002) ហើយប្រភេទឈើដែលដុះលូតលាស់លឿនត្រូវបានគេនិយមដោយសារការកើនមាឌឆាប់ និងខួបអាជីវកម្មខ្លី។ ក៏ប៉ុន្តែការដាំឈើជាទ្រង់ទ្រាយធំហើយមានតែមួយប្រភេទមិនអាចចាត់ទុកថាជាព្រៃបានទេព្រោះវាមិនអាចផ្តល់ផលប្រយោជន៍ដូចដែលព្រៃធម្មជាតិបានផ្តល់ឱ្យ។ ព្រៃប្រភេទនេះអាចនឹងបង្កផលប៉ះពាល់ជាអវិជមានដល់បរិស្ថានដូចជាកាត់បន្ថយជីវចំរុះ បង្កើនការហូរច្រោះ បំពុលទឹក និង បង្ករឱ្យមានកំទេចកំណរដី (ITTO, 1993) និងប៉ះពាល់ដល់ជីវភាពរស់នៅប្រចាំថ្ងៃនៅជនបទដោយសារការបាត់បង់សិទ្ធិចូលទៅកាន់ព្រៃឈើ និង ដីកសិកម្ម ដែលត្រូវកាន់កាប់ដោយក្រុមហ៊ុនដាំឈើ (Carrere, 2004a)។ ប្រអប់ទី១ បង្ហាញនូវការពតិនាខ្លះៗដែលគួរឱ្យ ចាប់អារម្មណ៍ អំពីការដាំឈើដោយប្រជាជនមូលដ្ឋាន។

**ប្រអប់ទី១-និយមន័យចំការឈើដាំ តាមការយល់ឃើញរបស់ប្រជាជនមូលដ្ឋាន**

| | |
|---|---|
| *ដើមឈើអាត្មានិយម (ថៃ)* | បឺតយកសារធាតុចិញ្ចឹមជាច្រើនពីដីហើយអាចដាំដំណាំឆ្លាស់បានតិចតួចបំផុត |
| *ទាហានដាំ (ឆាល)* | ដោយហេតុថាដើមឈើទាំងនោះមានពណ៌បៃតង ដាំជាជួរត្រង់ភ្លឹង ហើយជារឿយៗធ្វើចលនាទៅមុខ |
| *វាលរហោស្ថានបៃតង (ប្រេស៊ីល)* | មិនមានផ្តល់អាហារដល់សត្វព្រៃមិនផ្តល់ទីតាំងសំរាប់រុក្ខជាតិឯទៀត ហើយគ្មានប្រភពទំនិញ និងសេវាកម្មសំរាប់ប្រជាជនមូលដ្ឋាន |
| *មហារីកបៃតង (អាហ្វ្រិកខាងត្បូង)* | បំផ្លាញទឹក ដី សត្វព្រៃ រុក្ខជាតិ ជីវភាពរស់នៅរបស់មនុស្ស ហើយចុងបញ្ចប់ សំលាប់អ្វីៗទាំងអស់ |
| *ព្រៃប្លាស្ទិក (ឡាវ)* | ដែលមើលទៅដូចព្រៃ ប៉ុន្តែបើចូលទៅក្នុងគ្មានអ្វីដែលជាលក្ខណៈទូទៅដូចព្រៃទេ |

(Carrere, 2004a)

ទោះបីជាដុះលូតលាស់យឺត ប៉ុន្តែមានតម្លៃសេដ្ឋកិច្ចខ្ពស់ ប្រភេទឈើក្នុងស្រុកបានទាក់ទាញការយកចិត្តទុកដាក់យ៉ាងខ្លាំងទាំងខាងផ្នែកបរិស្ថាន និង សេដ្ឋកិច្ចហើយប្រភេទទាំងនេះបានបន្សាំខ្លួនទៅនឹងលក្ខណៈនៃទីកន្លែងរួចជាស្រេច។ ការធ្វើសមាហរណកម្មចូលទៅក្នុងដំណើការរៀបចំផែនការប្រើប្រាស់ដីដែលក្នុងនោះមានពិធីការក្នុងការធ្វើកិច្ចពិគ្រោះយោបល់ជាមួយនឹងសហគមន៍មូលដ្ឋាន អាចនឹងជួយកាត់បន្ថយនូវកង្វល់មួយចំនួនដែលលើកឡើងខាងដើម។

## ៥.៣.២ ចំការឈើចំរុះប្រភេទ

ចំការឈើចំរុះប្រភេទប្រហែលជាអាចធានានូវសុវត្ថិភាពនៃដើមទុនជាង ដោយហេតុថាវាមិនងាយទទួលរងនូវការបំផ្លាញពីសត្វល្អិតនិងជំងឺ ហើយគេអាចកាប់ដកហូតដើមឈើជាបណ្តើៗក្នុងរយៈពេលខុសៗគ្នា។ ខុសពីចំការឈើតែមួយប្រភេទ ចំការឈើចំរុះប្រភេទ(ប្រសិនបើបង្កើតឡើងដោយមានផែនការត្រឹមត្រូវ)មានសក្តានុពលខ្ពស់ក្នុងការការពារទីជំរាល ការអភិរក្សជីវចំរុះ និងធនធានសេនេទិក ហើយបង្កើនផលប្រយោជន៍ខាងផ្នែកសេដ្ឋកិច្ច និង អេកូឡូស៊ីសំរាប់សហគមន៍មូលដ្ឋានតាមរយៈការបង្កើតនូវទីកន្លែងមួយដែលមានលក្ខណៈសមស្របសំរាប់ សកម្មភាពរកប្រាក់ចំណូល ដូចជាកសិ-រុក្ខកម្មជាដើម។

## ៥.៤ ការដាំដើមឈើនៅលើដីចំការឯកជន

ការដាំដើមឈើនៅលើដីចំការឯកជនកំពុងពេញនិយមយ៉ាងខ្លាំងបន្ទាប់ពីការទទួលស្គាល់ថាទៅថ្ងៃអនាគតផលិតផលឈើនឹងមានប្រភពមកពីក្រៅតំបន់ព្រៃ។ ទោះបីជាមានលក្ខណៈតូចតាច ការដាំដើមឈើនៅលើដីចំការឯកជនមានលក្ខណៈនិរន្តរភាព ការចំណាយមានប្រសិទ្ធភាព និងជំរុញឱ្យមានសហគ្រិនភាពនៅមូលដ្ឋាន។ ក៏ប៉ុន្តែមានឧបសគ្គមួយចំនួនត្រូវបានគេប្រមើលមើលឃើញ ដូចជា ទន្ទឹមនឹងការបង្កើនផ្ទៃដីដាំដុះ នោះគេជួបប្រទះនូវបញ្ហាថវិកា (គ្មានប្រាក់កម្ចី) និងភាពនៅឆ្ងាយពីទីផ្សារ។ បញ្ហាទាំងអស់នោះអាចត្រូវដោះស្រាយដោយការជួយអន្តរាគមន៍តាមរយៈនយោបាយគាំទ្ររបស់រដ្ឋាភិបាល ដូចជាការលើកទឹកចិត្ត ការផ្តល់នូវប្រាក់ឧបត្ថម្ភធន និងសេវាកម្មគាំទ្រ ផ្សេងៗទៀត ព្រមទាំងការបង្កើតភាពជាដៃគូររវាងអ្នកកាន់កាប់ដីតូចតាច រដ្ឋាភិបាល និង ផ្នែកឯកជន (Pasicolan, 2003)។

នៅកម្ពុជា ជំរើសនេះមានលក្ខណៈក្មេងខ្ចីនៅឡើយ ហើយវិធីសាស្ត្រនេះគេគួររាប់បញ្ចូលផងដែរនូវៈ

- o ការដាំឈើជាលក្ខណៈពាណិជ្ជកម្មជាទ្រង់ទ្រាយតូច សំរាប់ទីផ្សារក្នុងស្រុក
- o សហគមន៍/អ្នកម៉ៅការតូចតាច ដើម្បីផលិតនូវផលិតផលអ្វីមួយ

## ៦. ដំណើរការក្នុងការកំណត់តំបន់អាទិភាពសំរាប់ដាំឈើ

(សូមមើលគំនូសតាង នៅក្នុងឧបសម្ព័ន្ធទី ១)

ដំណើរការក្នុងការកំណត់តំបន់អាទិភាពសំរាប់ដាំឈើត្រូវបានបំបែកជាជំហាន២ ដើម្បីឱ្យតំបន់ដែលមិនសមស្របសំរាប់ការងារដាំឈើត្រូវបានជំរុះចោលឱ្យបានឆាប់មុនពេលដែលធនធានជាច្រើនត្រូវបានចំណាយសំរាប់ការងារចុះសិក្សាទីតាំង។ នៅពេលដែលទីតាំងណាមួយត្រូវបានសិក្សាតាមរយៈជំហានជាបន្តបន្ទាប់ នោះគេនឹងទទួលបានពត៌មានកាន់តែច្រើនឡើង ដូច្នេះទាមទារឱ្យមានការចាប់អារម្មណ៍អំពីតំរូវការនៃថវិកា និង ធនធានមនុស្ស។

ជំហានទីមួយគឺជាការសិក្សានៅនឹងការិយាល័យ ដោយប្រើប្រាស់ផែនទីដែលមាននៅក្នុងឧបសម្ព័ន្ធទី ៥។ ជំហានជាបន្តបន្ទាប់ទៀតគឺជាការសិក្សានៅនឹងទីវាលជាក់ស្តែង។

### ៦.១ ជំហានទី១_កំណត់តំបន់ដែលអាចមានលទ្ធភាពដាំដើមឈើ

**គោលដៅៈ** កំណត់ទីតាំងដែលសមស្របសំរាប់បំពេញកម្មវត្ថុនានានៃការដាំឈើ ដោយប្រើប្រាស់ផែនទីនានា លក្ខណៈវិនិច្ឆ័យ និង សន្ទស្សន៍។